ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០២៥.....សហវ.......

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី៣១ខែ ធ្នូ ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី១ ជំហានទី ៣

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលដាក់ឱ្យដំណើរការប្រើប្រាស់ក្នុងដំណាក់កាលទី១ ជំហានទី១ និងជំហានទី២ រួចហើយ តាមរយៈសេចក្តីជូនដំណឹងលេខ០០២ សហវ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ និងសេចក្តីជូនដំណឹងលេខ០១៣ សហវ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។ ស្របជាមួយគ្នានេះដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS ដំណាក់កាលទី១ ជំហានទី៣ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ នេះតទៅ។

ក្នុងគោលបំណងឱ្យប្រព័ន្ធនេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់សាខាធនាគារពាណិជ្ជដៃគូ មេត្តាជ្រាបដូចតទៅ÷

ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ចំនួន១៨ ប្រើប្រាស់លេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត)។

ខ. នៅដំណាក់កាលទី១ ជំហានទី៣ នេះ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ដែលត្រូវអនុវត្ត រួមមាន÷ រដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, មន្ទីរព័ត៌មាន, មន្ទីរសុខាភិបាល, មន្ទីររ៉ែនិងថាមពល, មន្ទីរពាណិជ្ជកម្ម, មន្ទីរអប់រំ យុវជន និងកីឡា, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ, មន្ទីរបរិស្ថាន, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍, មន្ទីរសាធារណការនិងដឹកជញ្ជូន, សាលាដំបូង, មន្ទីរទេសចរណ៍, មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី, មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរឧស្សាហកម្មនិងសិប្បកម្ម។

គ.បេឡាករ នៃសាខាធនាគារពាណិជ្ជដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ឬ លេខកូដចំណូលដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ទៅក្នុងបង្កាន់ដៃបង់ប្រាក់ (កន្លែងបរិយាយ/អត្ថន័យនៃការបង់ចំណូល) ដើម្បីផ្តល់ភាពងាយស្រួល ក្នុងការផ្ទៀងផ្ទាត់ប្រភពចំណូលជាមួយមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ទាំង ១៨នោះ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ឃ. ក្នុងករណីដែលចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិទាំងឡាយណាពុំមានកំណត់លេខកូដទេនោះ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្តសាមី ពុំអាចបង់ចំណូលទាំងនោះបានឡើយ ហើយត្រូវស្នើសុំតាមរយៈក្រសួង ស្ថាប័នអាណាព្យាបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដើម្បីអនុម័តលេខកូដជូន។

ង. អតិថិជន ឬ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្តសាមី មិនអាចបង់សាច់ប្រាក់ចូលគណនីទោលរតនាគារ (TSA) នៅរាជធានី ខេត្ត ឬ គណនីធនាគារពាណិជ្ជរបស់រដ្ឋទេយ្យករចំណូលតិចជាង ឬ ច្រើនជាងទឹកប្រាក់នៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ឡើយ។

ការរៀបចំលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ (ចំណូលពីសេវាសាធារណៈ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) ត្រូវបានកំណត់ជាទម្រង់ ដូចខាងក្រោម÷

**លេខកូដបង់ចំណូលថ្នាក់ជាតិ÷** MMM-TT-*៩៩៩៩*

- MMM : លេខកូដរបស់ក្រសួង ស្ថាប័ន ឬ អង្គភាព (3 ខ្ទង់ខាងមុខ)
- TT : ប្រភេទចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (2 ខ្ទង់បន្ទាប់)
- ៩៩៩៩ : លេខរៀងចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (4 ខ្ទង់ចុងក្រោយ)

❖ ***កំណត់សំគាល់*** (TT) ÷

ក. ផ្នែកកូដចំណូលពីសេវាសាធារណៈ លេខ 01

ខ. ផ្នែកកូដចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷ 02 ការជួល, 03 ភាគលាភ, 04 ចំណូលពីកាតព្វកិច្ចកាស៊ីណូ, 05 សម្បទាន, 06 ផលនេសាទ, 07 ចំណូលពីអាកាសចរស៊ីវិល (053070001 Credit Loan,053070002 Airport Division Supervisory (ADS Profit Sharing), 08 ផ្សេងៗ, 09 ពិន័យ, 10 ចំណូលពីកាតព្វកិច្ចឆ្នោត និង 11 ផលពីសម្បទាន។

➢ <u>ឧទាហរណ៍ទី១</u>÷ ចំណូលពីសេវាសាធារណៈ÷

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 110010001។

- 110 = ក្រសួងព័ត៌មាន (ឈ្មោះក្រសួង ស្ថាប័ន)
- 01 = ប្រភេទចំណូលពីសេវាសាធារណៈ (ប្រភេទចំណូលសេវា)
- 0001 = លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)

ខ្លឹមសារ÷ ផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ - រយៈពេល 1 ឆ្នាំ។

➢ <u>ឧទាហរណ៍ទី២</u>÷ ចំណូលពីសេវាសាធារណៈ÷

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 190010001។

ខ្លឹមសារ÷ ប្រាក់ពិន័យបទល្មើសធនធានធម្មជាតិ ពិន័យអន្តរការណ៍ (បទល្មើសធនធានធម្មជាតិថ្នាក់ទី1)។

➢ <u>ឧទាហរណ៍ទី៣</u>÷ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 054020001។

ខ្លឹមសារ÷ ចំណូលពីការជួល កោះអូន កោះបង ក្រុងព្រះសីហនុ។

➢ <u>ឧទាហរណ៍ទី៤</u>÷ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 110020001។

ខ្លឹមសារ÷ ចំណូលពីការជួល អគារលេខ ២៦២ មហាវិថីព្រះមុន្នីវង្ស (សណ្ឋាគារមិត្តភាព)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាខាធនាគារពាណិជ្ជដៃគូ មេត្តាជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព ព្រមទាំងចូលរួមផ្តល់មតិកែលម្អសម្រាប់ការងារអនុវត្តទៅថ្ងៃអនាគត។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល÷</u>**

- ធនាគារពាណិជ្ជដៃគូ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ